## អាជីវកម្មថ្មីរបស់សហជីព ការបង្កើតគេហទំព័រជូនដល់ក្រុមហ៊ុន

អាជីវកម្មថ្មីរបស់សហជីពអាស៊ីក្រិតសិនគឺការបង្កើតគេហទំព័រដល់ក្រុមហ៊ុនជាសមាជិករបស់សហជីព។មិនត្រឹមតែបង្កើតគេហទំព័រតែប៉ុណ្ណោះទេថែមទាំងធ្វើបច្ចុប្បន្នភាពជូនថែមទៀតផង។

### គុណសម្បត្តិដែលទទួលបានពីគេហទំព័រ

វាប្រៀបដូចជាការសាងសង់ផ្ទះមួយការរចនាដំបូងនៃគេហទំព័រគឺមានសារៈសំខាន់ខ្លាំងណាស់។សហជីពស្គាល់យ៉ាងច្បាស់ពីក្រុមហ៊ុនដែលជាសមាជិក។ ហើយក៏យល់ច្បាស់ពីវិស័យសំណង់ថាតើពត៌មានបែបណាដែលត្រូវបង្ហោះនៅលើគេហទំព័ររបស់ក្រុមហ៊ុនអ្នក។ហើយពត៌មានទាំងនោះវានឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរចនានៃគេហទំព័រ។

### គេហទំព័រដែលសាមញ្ញនិងងាយស្រួលប្រើ

គេហទំព័រ ត្រូវបង្កើតឡើង ដោយប្រើប្រាស់ កម្មវិធីវើដព្រេស (WordPress)។ វើដព្រេសមានការរចនាស្អាត និងមានមុខងារក្នុងការគ្រប់គ្រងយ៉ាងងាយស្រួល។ លើសពីនេះទៀតវាងាយស្រួលក្នុងការកែសម្រួល ដូច្នេះការធ្វើបច្ចុប្បន្នភាពការងារអាចធ្វើបានយ៉ាងងាយស្រួលផងដែរ។

### ព្រឹក្សាយោបល់បានគ្រប់ពេល

ទោះបីវាជាគេហទំព័រលើកដំបូងសំរាប់ក្រុមហ៊ុនរបស់អ្នកក៏ដោយ ក៏វាមិនមានបញ្ហាអ្វីដែរយើងខ្ញុំនិងពន្យល់បកស្រាយជូនយ៉ាងលំអិត។ ប្រសិនបើក្រុមហ៊ុនរបស់អ្នកមានគេហទំព័រហើយក៏ដោយ យើងក៏មានទទួលកែលំអរទៅលើរចនាបទផងដែរ។ សូមព្រឹក្សាយោបល់ជាមួយអ្នកទទួលបន្ទុកបង្កើតគេហទំព័ររបស់សហជីព។

## ក្រុមហ៊ុនត្រូវរាយការណ៍ម៉ោងធ្វើការឲ្យបានត្រឹមត្រូវ

នៅប្រទេសជប៉ុន ច្បាប់ការងារត្រូវបានកែសម្រួលតាំងពី ខែមេសា ឆ្នាំ2019 មកដើម្បីអនុញ្ញាតឱ្យនិយោជិកជ្រើសរើសពីទម្រង់ការងារផ្សេងៗគ្នា។ ច្បាប់ថ្មីតម្រូវឱ្យក្រុមហ៊ុនកត់ត្រាម៉ោងធ្វើការ របស់និយោជិកឱ្យបានត្រឹមត្រូវ។

លើសពីនេះទៅទៀតក្រុមហ៊ុនគឺ ត្រូវតែកត់ត្រាលើចំនួនម៉ោងធ្វើការរបស់និយោជិកម៉ោងថែម ម៉ោងធ្វើការប្រាក់បៀវត្សរ៍គោល និងចំនួនទឹកប្រាក់ ដែលត្រូវបានកាត់លើការស្នើសុំ10ចំណុចជាដើមក្នុងសៀវភៅកំណត់របស់ច្បាប់។

កាតព្វកិច្ចរបស់ក្រុមហ៊ុន ក្នុងការដាក់ស្នើរសៀវភៅកត់ត្រាទៅរដ្ឋាភិបាល។

ប្រសិនបើអ្នកផ្លាស់ប្តូរចំនួនម៉ោងធ្វើការឬគូរលេខផ្សេងទៀតដោយចេតនាក្រុមហ៊ុនអាចនឹងត្រូវពិន័យ។

រាយការណ៍ឱ្យបានច្បាស់លាស់អំពីម៉ោងធ្វើការរបស់និយោជិក។

## បើមានគំរោងត្រលប់ទៅប្រទេសរបស់ខ្លួនជាបណ្តោះ អាសន្នសូមធ្វើការពិភាក្សាអោយបានលឿន

ចំពោះសិក្ខាកាម ការបណ្តុះបណ្តាលបច្ចេកទេសក្នុងការស្នាក់នៅ មានរយៈពេល3ឆ្នាំ។ ជាគោលការមិនអាចត្រលប់ទៅប្រទេសជាបណ្តោះអាសន្នវិញបានដូច្នេះ ចំពោះប្រព័ន្ធច្បាប់សិក្ខាកាម ការវិលត្រលប់ទៅប្រទេសជាបណ្តោះអាសន្នវិញ គឺមិនមាននោះទេ។

ទោះបីយ៉ាងនេះក៏ដោយក៏មានករណីខ្លះយើងត្រូវតែត្រលប់ទៅប្រទេសរបស់ខ្លួនជាបណ្តោះអាសន្នវិញជាចាំបាច់ ដូចជាក្នុងករណីគ្រួសារបានជួបរឿងមិនល្អជាដើម។ ក្នុងករណីបែបនេះការត្រលប់ទៅប្រទេសជាបណ្តោះអាសន្នវិញ អាចធ្វើទៅបាន។

ប៉ុន្តែការត្រលប់ទៅប្រទេសវិញជាបណ្តោះអាសន្ន មិនអាចធ្វើទៅតាមចិត្តខ្លួនឯងបាននោះទេ។ ការត្រលប់ទៅប្រទេសវិញជាបណ្តោះអាសន្ន វានឹងធ្វើអោយប៉ះពាល់ដល់គម្រោងនៃការបណ្តុះបណ្តាល និង ដំណើរការការងាររបស់ក្រុមហ៊ុនផងដែរ។

ម្យ៉ាងវិញទៀត ចំពោះនិតិវិធី ក្នុងការវិលចូលប្រទេសវិញជាដើមនោះគឺ សិក្ខាកាមមិនអាចធ្វើដោយខ្លួនឯងបាននោះឡើយ។

ចំពោះសិក្ខាកាម ដែលចង់វិលត្រលប់ទៅប្រទេសវិញជាបណ្តោះអាសន្ន ត្រូវពិភាក្សាជាមួយស្ថានប័នគ្រប់គ្រង និងក្រុមហ៊ុនអោយបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។

## អត្រាភាគរយនៃការទទួលបន្ទុកលើធានារ៉ាប់រងការងារនឹងមានការកើនឡើង

នៅឆ្នាំ2022 អត្រាភាគរយនៃការទទួលបន្ទុកលើធានារ៉ាប់រងការងារនឹងមានការកើនឡើង គឺដោយសារ ដើម្បីធានាថវិការជាតិដើម្បីទប់ស្កាត់ជំងឺកូវីដ19។

ទំហំបន្ទុករបស់ក្រុមហ៊ុន មានការកើនឡើងពីរដងផងដែរ គឺ នៅថ្ងៃទី01 ខែមេសា និង ថ្ងៃទី01 ខែតុលា។

អត្រាភាគរយទទួលបន្ទុករបស់កម្មករនយោជិក (រួមទាំងសិក្ខាកាមផង) នឹងកើនឡើងម្តង នៅថ្ងៃទី01ខែតុលាខាងមុខនេះ។ ភាគរយទទួលបន្ទុក នឹងត្រូវបានកំណាត់តាមប្រភេទការងារ។

### សម្រាប់កម្មករសំណង់

ចាប់ពី ថ្ងៃទី01ខែតុលាឆ្នាំ2022នេះទៅនឹងមានអត្រាទទួលបន្ទុកដូចខាងក្រោម

4/1000－＞6/1000

ឧទាហរណ៍៖ ក្នុងករណីប្រាក់ខែ 200,000 យ៉េន

មុខថ្ងៃ ទី01 ខែតុលា : 200,000យ៉េនx 0.004= 800យ៉េន

▼

ក្រោយថ្ងៃ ទី01 ខែតុលា : 200,000យ៉េនx 0.006=1,200 យ៉េន (+400យ៉េន)

### សូមប្រុងប្រយត្ន័ចំពោះប្រាក់ខែក្រោយ ថ្ងៃទី01 ខែតុលា

ធានារ៉ាប់រងការងារគឺ មានលំអិតនៅរបស់ប្រាក់ខែគេដាក់បញ្ចូលនៅក្នុង "លុយកាត់ = ប្រាក់មិនជាប់ពន្ធ"។ ចាប់ពីថ្ងៃទី01 ខែតុលានេះទៅទឹកប្រាក់ដែលត្រូវកាត់នោះ នឹងមានការកើនឡើង(ដូចដែលមាន នៅក្នុងឧទាហរណ៍ខាងលើ)ហើយចំណែកនោះនឹងត្រូវកាត់ពីប្រាក់ខែរបស់យើង។សូមប្រុងប្រយត្ន័។

## ការណែនាំអំពីបុគ្គលិកសហជីព



ផ្នែករដ្ឋបាល

**គិស៊ិម៉ុតុ កាហ្សិណូរី**

**ការងារ:** ពីមុនខ្ញុំបានធ្វើការផ្នែកស្នើរសុំឯកសារដើម្បីធានាសិក្ខាកាមមកប្រទេសជប៉ុន។ ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំទទួលបន្ទុកខាងផ្នែកស្នើរឯកសារដើម្បីធានាពលករជំនាញវិញម្តង។ នីតិវិធីសម្រាប់ប្រព័ន្ធសិក្ខាកាម មានភាពស្មុគស្មាញ និងពិបាក។ ក៏ប៉ុន្តែយើងត្រូវជំនះភាពលំបាក នឹងខិតខំប្រមូលបទពិសោធន៍ពីការងារបន្ថែមទៀត។

**ឯកជន:** អាហារ ស្រា នឹងហ្គេមគឺជាចំណង់ចំណូលចិត្តរបស់ខ្ញុំ។ កូវីដ19បានជះឥទ្ធិពលដល់ជីវិតរបស់ខ្ញុំបរិមាណគ្រឿងស្រវឹងដែលខ្ញុំផឹកបានកើនឡើងហើយសម្ពាធឈាមរបស់ខ្ញុំក៏កើនឡើងបន្តិចម្តងៗ។ ខ្ញុំកំពុងតែព្យាយាមកែលំអតាមរយៈការហាត់ប្រាណ។



ផ្នែករដ្ឋបាល

**RayamajiSabin**

**ការងារ:** ខ្ញុំទទួលបន្ទុក ខាងផ្នែកគ្រប់គ្រងទិន្នន័យរយៈពេលនៃការស្នើសុំឯកសារនិងរយៈពេលរបស់លិខិតសិទ្ធស្នាក់នៅរបស់សិក្ខាកាម។

**ឯកជន:** ខ្ញុំចូលចិត្តទំនាក់ទំនង ជាមួយមនុស្សជាច្រើនមកពីប្រទេសផ្សេងៗ។ ខ្ញុំចូលរួមយ៉ាងសកម្មនៅក្នុងព្រឹត្តិការណ៍សហគមន៍ នៅក្នុងតំបន់ដែលខ្ញុំរស់នៅ។ ពេលខ្លះខ្ញុំបានធ្វើការីនេប៉ាល់ ដូចទៅនឹងរសជាតិដើមរបស់ប្រទេសខ្ញុំហើយបានអោយអ្នកជិតខាងញុាំផងដែរ។